# អង្គការ អភិវឌ្ឍន៍ និង ភាពជាដៃគូ ក្នុងសកម្មភាព( ឌីភីអេ )

## ការប្រកាសអញ្ជើញចូលរួមធ្វើការដេញថ្លៃ ការសាងសង់ប្រព័ន្ធធារាសាស្ត្រ

អង្គការអភិវឌ្ឍន៍ និងភាពជាដៃគូ ក្នុងសកម្មភាព (**ឌីភីអេ**) ជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលមានកម្មវិធីធំៗចំនួនពីរគឺ ៖ កម្មវិធីអភិវឌ្ឍន៍សហគមន៍ចំរុះ និងកម្មវិធីភាពជាដៃគូ និងតស៊ូមតិ ។ កម្មវិធីអភិវឌ្ឍន៍សហគមន៍ចំរុះអនុវត្តដោយ ផ្ទាល់នៅក្នុងខេត្ត៦ គឺៈ ខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ព្រះវិហារ កំពង់ធំ និង សៀមរាប ។ អង្គការ **ឌីភីអេបានទទួលថវិការពីអង្គការ** MANOS UNIDAS **ដើម្បីសាងសង់ប្រព័ន្ធធារាសាស្រ្ត ជូនដល់ប្រជាពលរដ្ឋនៅក្នុងស្រុកជីក្រែងខេត្តសៀមរាប**

- **គោលបំណងនៃការអញ្ជើញះ**

អង្គការអភិវឌ្ឍន៍ និងភាពជាដៃគូ ក្នុងសកម្មភាព កំពុងធ្វើការស្វែងរកក្រុមហ៊ុនសាងសង់ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុងការផ្តល់សេវាកម្ម សាងសង់ប្រព័ន្ធធារាសាស្រ្ត (**សាងសង់ប្រឡាយទឹកចំនួន២ សាងសង់ទ្វាទឹកចំនួន១១ និងស្ពាប្រឡាយទឹកចំនួន ៦** ) នៅតាមតំបន់គោលដៅមានភូមិ អូរលើ ភូមិអូរក្រោម ភូមិថ្នល់លោក ភូមិថ្នល់កែង ភូមិក្វានពង ក្នុងស្រុកជីក្រែង ខេត្តសៀមរាប។

**ក្រុមហ៊ុនសាងសង់ ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោមដើម្បីដាក់ពាក្យដេញថ្លៃះ**

- ត្រូវមានវិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជកម្ម ពីក្រសួងពាណិជ្ជកម្ម
- ត្រូវមានប័ណ្ណប៉ាតង់ប្រកបអាជីវកម្ម និងវិញ្ញាបនប័ត្រចុះបញ្ជីពន្ធដារ ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ត្រូវមានគ្រឿងចក្រគ្រប់គ្រាន់សម្រាប់សាងសង់ប្រព័ន្ធធារាសាស្រ្ត
- យល់ព្រមគោរពតាមគោលនយោបាយស្តីពីការការពារកុមាររបស់អង្គការឌីភីអេ
- យល់ព្រមគោរពតាមច្បាប់ស្តីពីកម្រៃជើងសារវង្វាន់ និងសំណូកសូកប៉ាន់របស់អង្គការឌីភីអេ
- ត្រូវមានបទពិសោធន៍ក្នុងការសាងសង់ប្រព័ន្ធធារាសាស្រ្ត

**របៀបចូលរួមះ**

1. សូមធ្វើការទំនាក់ទំនងមកកាន់ អង្គការឌីភីអេ ពីផ្នែកលទ្ធកម្ម និងរដ្ឋបាល ដែលមានអស័យដ្ឋាន ផ្ទះលេខ ០៣ ផ្លូវលេខ៣២៣ សង្កាត់បឹងកក់ទី២ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ដើម្បីទទួលបានពត៌មានលំអិត និងមកទទួលបែបបទផ្សេងៗ ដើម្បីដាក់ពាក្យដេញថ្លៃ ចាប់ពីថ្ងៃផ្សាយដំណឹងនេះ រហូតដល់កាលបរិច្ឆេទឈប់ទទួលពាក្យដេញថ្លៃ
2. ធ្វើការបំពេញបែបបទដេញថ្លៃទាំងនោះហើយ ដាក់ក្នុងស្រោមសំបុត្របិទជិត និងធ្វើការបញ្ជូនមកកាន់ការិយាល័យ អង្គការឌីភីអេ តាមអស័យដ្ឋានដែលបានបញ្ជាក់ខាងលើ រឺការិយាល័យអង្គការឌីភីអេនៅភូមិកំពង់ក្តី១ ឃុំកំពង់ក្តី ស្រុកជីក្រែង ខេត្តសៀមរាប។
3. អង្គការឌីភីអេ ទន្ទឹងរង់ចាំទទួលពាក្យដេញថ្លៃរបស់លោកអ្នក ចាប់ពីថ្ងៃផ្សាយដំណឹងនេះ រហូតដល់ថ្ងៃផុតកំណត់ទទួលពាក្យ ថ្ងៃទី១៦ ខែមិនា ឆ្នាំ២០១៨ វេលាម៉ោង៥:០០រសៀល។

អង្គការឌីភីអេលើកទឹកចិត្តអោយក្រុមហ៊ុនដេញថ្លៃចូលរួមក្នុងការបើកពាក្យដេញថ្លៃដែលប្រព្រឹត្តទៅនៅថ្ងៃទី២០ ខែមិនា ឆ្នាំ២០១៨ នៅសាលាឃុំស្ពានត្នោត មានអស័យដ្ឋាននៅភូមិថ្នល់កែង ឃុំស្ពានត្នោត ស្រុកជីក្រែង ខេត្តសៀមរាបវេលាម៉ោង៩ព្រឹកគត់។

អង្គការឌីភីអេ សូមអរគុណជាមុន សម្រាប់ចំណាប់អារម្មណ៍របស់អ្នក ចំពោះឱកាសជ្រើសរើស អ្នកផ្គត់ផ្គង់របស់អង្គការឌីភីអេ។